**ព្រះរាជាណាចក្រកម្ពុជា**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** **ជាតិ សាសនា ព្រះមហាក្សត្រ**

**អង្គភាពគ្រប់គ្រងគម្រោង** (PMU )

# កំណត់ហេតុអង្គប្រជុំ

## *ស្តីពី " បញ្ហាប្រឈមមុខនៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ "*

ឆ្នាំពីរពាន់ប្រាំពីរ ខែធ្នូ ថ្ងៃទីដប់ប្រាំបី វេលាម៉ោងដប់បួននិងសាមសិបនាទីរសៀល នៅបន្ទប់សាលប្រជុំរបស់វិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ( NTTI ) មានបើកអង្គប្រជុំស្តីពី " បញ្ហាប្រឈមមុខនៅក្នុងការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ" ក្រោមអធិបតីភាព *ឯកឧត្តម ពេជ សោភ័ន* រដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងសមាសភាពអញ្ជើញចូលរួមដូចមានភ្ជាប់ក្នុងបញ្ជីវត្តមាន ។

ជាកិច្ចចាប់ផ្តើម *ឯកឧត្តម* ប្រធានអង្គប្រជុំបានសំដែងការស្វាគមន៍ដល់ឯកឧត្តម លោក លោកស្រី និងនាងកញ្ញាដែលបានអញ្ជើញចូលរួមមាននាយកដ្ឋានក្រោមឱវាទក្រសួងចំនួន ៣ ( ន .គ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ,ន.ស្តង់ដាជាតិសមត្ថភាព និងន.ព័ត៌មានទីផ្សារការងារ) គ្រឹះស្ថានសិក្សាសាធារណៈចំនួន ៨ និងគ្រឹះស្ថានសិក្សាឯកជន- NGO ចំនួន ៤ និងមន្ត្រីដៃគូជាតិ -អន្តរជាតិទាំងអស់ ។

បន្ទាប់មក*ឯកឧត្តម* បានមានប្រសាសន៍អំពីស្ថានភាពទូទៅនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ហើយក្នុងនោះ ឯកឧត្តម បានលើកឡើងពីផែនការជាតិ១៤ ចំនុច ស្តីពីការអភិវឌ្ឍលើវិស័យនេះ ដោយភ្ជាប់មកជាមួយបេសកកម្មជាយុទ្ធសាស្រ្តមាន ២ ចំនុចធំៗ គឺយុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រមានន័យថាយើងផ្តល់ជំនាញដល់ប្រជាពលរដ្ឋនៅតាមទីជនបទ និងតំបន់ដាច់ស្រយាលនានាដើម្បីឱ្យពួកគេមានជំនាញ និងសមត្ថភាពគ្រប់គ្រាន់ ដើម្បីប្រកបមុខរបរចិញ្ចឹមគ្រួសារ និងជួយជំរុញសេដ្ឋកិច្ចសង្គម និងមួយទៀតគឺការត្រៀមលក្ខណៈសំរាប់បំរើវិស័យឧស្សាហកម្មតាមរយៈការបណ្តុះបណ្តាលរយៈពេលវែង និងមានសមត្ថភាពខ្ពស់ហើយឆ្លើយតបបានតម្រូវការទីផ្សារ ឧស្សាហកម្ម ។

ឆ្លើយតបបញ្ហានេះ សព្វថ្ងៃយើងមានការព្រួយបារម្ភណ៍យ៉ាងខ្លាំងលើកំនើនសិស្សានុសិស្សដែលបានបញ្ចប់ការសិក្សាចំណេះទូទៅនៅថ្នាក់ទី ១២ បើតាមស្ថិតិរបស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅរបស់ក្រសួងអប់រំ យុវជន និងកីឡាបានបង្ហាញថា មានសិស្សានុសិស្ស ប្រហែលជាងពី ៦០.០០០-៧០.០០០នាក់ ជារៀងរាល់ឆ្នាំ ហើយក្នុងនោះមួយចំនួនធំបានចុះឈ្មោះចូលរៀននៅគ្រឹះស្ថានឧត្តមសិក្សា និង មួយចំនួនតូចបានចូលរៀនក្នុងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ចុះមួយចំនួនទៀតទៅទីណា? នេះជាការព្រួយបារម្ភណ៍របស់រាជរដ្ឋាភិបាល ។ ពេលនេះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំងអស់ត្រូវយកចិត្តទុកដាក់ដើម្បីគៀងគរប្រមូលសិស្សានុសិស្សទាំងនោះមកបណ្តុះបណ្តាលជំនាញ ហើយម្យ៉ាងវិញទៀតនោះ យើងកំពុងតែប្រឈមជាមួយបញ្ហា*សិស្សពុំចង់ចុះឈ្មោះចូលរៀននៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ* ។ ពាក់ព័ន្ធបញ្ហានេះ វាអាចកើតចេញពីតម្រូវការទីផ្សារការងារ ត្រូវការអ្នកដែលមានសញ្ញាប័ត្រខ្ពស់ ឬថាសមត្ថភាពរបស់គ្រឹះស្ថានសិក្សាយើងនៅមានកំរិតជាពិសេសសមត្ថភាពបុគ្គលិក មន្ត្រីរាជការ លោកគ្រូ អ្នកគ្រូ ដែលមួយចំនួនធំពុំបានស្រាវជ្រាវស្វែងយល់ពីស្ថាន ភាពបច្ចុប្បន្ន ឬមួយកំរើកំលាំងពលកម្មខុសគ្នាខ្លាំងពីកំរិតសញ្ញាប័ត្រមួយទៅកំរិតមួយទៀតដែលខ្ពស់ជាង? ។ រឿងនេះយើងទាំងអស់គ្នាត្រូវគិតឡើងវិញ ហើយពិនិត្យមើលៈ

១-តើធ្វើដូចម្តេចដើម្បីឱ្យសិស្សចូលរៀន TVET បានច្រើន ?

២-តើត្រូវធ្វើដូចម្តេចដើម្បីឱ្យសិស្សរៀនផ្នែក TVET ពេលបញ្ចប់ការសិក្សាមានការងារធ្វើ ?

☞ **MR. SAM IAN CUMMINGS** :បានពិនិត្យឃើញថា មានបញ្ហាមួយចំនួនដូចជា:

-ការងារគ្រប់គ្រងនៅតាមគ្រឹះស្ថានសិក្សា គួររៀបចំបង្កើនចំណេះដឹងដល់អ្នកគ្រប់គ្រងគ្រឹះស្ថានសិក្សាតាមខេត្ត-ក្រុង ដើម្បីធានានូវការគ្រប់គ្រងឱ្យមានគុណភាពល្អ

-ការពង្រឹងសមត្ថភាពដោយផ្តោលើ :

- ✓ អភិវឌ្ឍន៍ធនធានមនុស្សតាមរយៈការបណ្តុះបណ្តាលបង្កើនសមត្ថភាព
- ✓ អាគារប្រើទាំង ០២ ពេល ( ថ្ងៃ និង យប់)

-ប្រទេសភាគច្រើនជ្រើសរើសគ្រូពីផ្នែកឯកជន

-ពង្រឹងគុណភាពគ្រូ និងសិស្ស - និស្សិត ដោយបង្កើនជំនាញបន្ថែម ( Core Skill ) ឧទាហរណ៍ ជំនាញទំនាក់ទំនង ភាសា IT ដែលជាមធ្យោបាយសំខាន់ក្នុងការស្វែងរកការងារធ្វើ

-ដើម្បី TVET ខ្លាំងគួរតែបណ្តុះបណ្តាលអ្នកគ្រប់គ្រងគ្រប់ខេត្ត-ក្រុង ហើយអ្នកបង្រៀនត្រូវមានសមត្ថភាព

-ត្រូវរៀបចំគុណវុឌ្ឍន៍ជាតិ គឺទាក់ទងទៅនឹងផ្នែករោងចក្រកាត់ដេរ ផ្នែកទេសចរណ៍ និងផ្នែកកសិពាណិជ្ជកម្ម ព្រោះនៅតាមរោងចក្រគេត្រូវការជំនាញដើម្បីធ្វើការងារ

-គោលនយោបាយក្នុងការចូលរួមរៀបចំ និងពង្រឹងគុណភាពបណ្តុះបណ្តាលត្រូវត្រូវផ្តោតលើ :

- ✓ អភិវឌ្ឍនធនធានមនុស្ស
- ✓ ពិនិត្យ និងកែលំអនូវអ្វីដែលពួកគាត់បានធ្វើកន្លងមក
- ✓ បង្កើនចំណេះដឹងដល់អ្នកគ្រប់គ្រង
- ✓ គ្រូបង្រៀនត្រូវបង្កើនសមត្ថភាព
- ✓ ស្ទាបស្ទង់តម្រូវការតាមខេត្ត-ក្រុង
- ✓ រៀបចំគោលការណ៍ណែនាំពីកម្មវិធីសិក្សា
- ✓ រៀបចំប្រព័ន្ធព័ត៌មានទីផ្សារការងារ
- ✓ រដ្ឋសហការជាមួយផ្នែកឯកជន រោងចក្រ ក្រុមហ៊ុន សហគ្រាស និងវិស័យផ្សេងៗ

☞ **លោក ហឿន សុផុន**

TVET ត្រូវធ្វើយ៉ាងណាពេលសិស្ស និស្សិតរៀនចប់ ត្រូវរកការងារឱ្យពួកគេមានការងារធ្វើ

- ✓ TVET ត្រូវពង្រឹងសមត្ថភាព និងគុណភាពបណ្តុះបណ្តាល
- ✓ TVET ត្រូវមានហេដ្ឋារចនាសម្ព័ន្ធល្អទៅតាមគ្រឹះស្ថានសិក្សានិមួយៗ
- ✓ TVET ត្រូវរៀបចំឱ្យមានប្រព័ន្ធព័ត៌មានទីផ្សារការងារឱ្យបានល្អ សំរាប់សិស្ស និស្សិត

☞ **MR.TOM NORTON**

- ✓ គ្រឹះស្ថានសិក្សាប្រៀបបានរោងចក្រមួយ ដូចនេះត្រូវពង្រឹងគុណភាពផលិតផលរបស់ខ្លួនផង និងការងារគ្រប់គ្រងរបស់ខ្លួនផង

✓ គ្រឹះស្ថានសិក្សានិមួយៗត្រូវការផ្សព្វផ្សាយព័ត៌មានរបស់ខ្លួនឱ្យបានទូលំទូលាយ

✓ ត្រូវមានផ្លូវល្អដើម្បីឱ្យគេចូលមករៀនបានស្រួល

✓ ត្រូវរៀបចំឱ្យមានស្លាកសញ្ញាឱ្យបានល្អ

✓ បង្កើតមជ្ឈមណ្ឌលព័ត៌មានទីផ្សារការងារនៅតាមគ្រឹះស្ថានសិក្សា TVET

☞ **ឯកឧត្តម ប៊ុន ភារិន** : បានលើកឡើងនូវបញ្ហាទូទៅមួយចំនួនថាប្រទេសកម្ពុជា ជាប្រទេសមួយដែលមានសក្តានុពលលើវិស័យកសិកម្ម ៦៥% ឧស្សាហកម្ម ២០% និងទេសចរណ៍ រួមជាមួយសេវាកម្មធុនតូច ១៥% ។ សព្វថ្ងៃមានសាលាបច្ចេក ទេសធំៗបួន នៅភ្នំពេញសិស្សចេញទៅប្រហែល ៣.០០០នាក់ មានការងារធ្វើប្រហែល ៧០% ហើយប្រាក់ខែ ពី ៨០ដុល្លាឡើង ដូចជាផ្នែកសំណង់បណ្តុះបណ្តាលមិនទាន់ចប់មានការងារធ្វើភ្លាម រីឯផ្នែករថយន្តយកទៅធ្វើតាមយានដ្ឋានជួសជុលគេពុំសូវទទួលយកដោយសិស្សពុំមានសមត្ថភាពគ្រប់គ្រាន់ ។ ដូចនេះ យើងមានទីផ្សារពីរគឺ ទីផ្សារសាលា និងទីផ្សារការងារ ។

☞ **លោក ប៉ាន់ ណូរ៉ា**

✓ យើងត្រូវពិនិត្យលើខ្លួនឯងជាមុនសិនពីបញ្ហា SWOT ហើយយើងត្រូវទទួលយកចំនុចខ្សោយរបស់យើងមកកែលំអ

✓ រៀបចំឱ្យមានកម្មវិធីសិក្សារួមមួយសំរាប់គ្រឹះស្ថានសិក្សា TVET

✓ អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវធ្វើ Marketing រួមដ៏ធំមួយ ដើម្បីផ្សព្វផ្សាយ

✓ គ្រឹះស្ថានសិក្សានិមួយៗបង្រៀនរបៀបរកការងារធ្វើ និងបង្កើតការងារឱ្យធ្វើ

☞ **ឯកឧត្តម រ័ត្ន ប៊ុនឡា**

✓ ត្រូវពង្រីកកម្មវិធីបណ្តុះបណ្តាលតាមប្រព័ន្ធលិខិតបញ្ជាក់បន្ថែមទៀត ព្រោះជោគជ័យណាស់សំរាប់កម្មវិធី TVET

✓ នាយកសាលានិមួយៗត្រូវអនុវត្តការងារគ្រប់គ្រងតាមបែបសហគ្រិន សហគ្រាស ឧស្សាហកម្ម ដើម្បីផ្គត់ផ្គង់ទីផ្សារពលកម្ម

✓ អគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈត្រូវធ្វើ Spot មួយដើម្បីផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍

☞ **លោក ណុប ធីម**

✓ សាលាត្រូវធ្វើការសិក្សាស្រាវជ្រាវទៅលើទីផ្សារបច្ចុប្បន្ន ដោយលើកបទពិសោធន៍របស់គាត់មកបញ្ជាក់បន្ថែមថាគាត់បានស្រាវជ្រាវតាំងពីចំនួនរថយន្ត ចំនួនយានដ្ឋានជួសជុល និងចំនួនអ្នកបច្ចេកទេសនៅតាមយានដ្ឋានជួសជុលនីមួយៗមានតម្រូវការប៉ុន្មាន ។

បន្ទាប់ពីបានពិភាក្សាគ្នាយ៉ាងផុលផុសក្នុងបរិយាកាសស្និតស្នាលរីករាយអស់រយៈពេលប៉ុន្មានម៉ោងក្រោមប្រធានបទពីរដែលលើកឡើងខាងលើ *ឯកឧត្តម* ប្រធានអង្គប្រជុំបានធ្វើការបូកសរុបលទ្ធផលនៃការប្រជុំដូចខាងក្រោមៈ

✓ ពង្រឹងសមត្ថភាពធនធានមនុស្ស

✓ អភិវឌ្ឍសំភារៈមូលដ្ឋាន

✓ ធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយ ដើម្បីឱ្យសាធារណៈជនបានជ្រាបពីសកម្មភាព TVET

✓ ពង្រឹង និងពង្រីកភាពជាដៃគូជាមួយវិស័យឯកជន

✓ រៀបចំឱ្យមានប្រព័ន្ធព័ត៌មានទីផ្សារការងារនៅតាមគ្រឹះស្ថានសិក្សាតាមរយៈការបង្កើតមជ្ឈមណ្ឌលព័ត៌មាន ទីផ្សារ

ការងារ

ជាចុងបញ្ចប់ *ឯកឧត្តម រដ្ឋលេខាធិការ* បានជូនពរដល់ ឯកឧត្តម លោក លោកស្រី ដែលអញ្ជើញមកពីនាយកដ្ឋានក្រោមឱវាទក្រសួង វិទ្យាស្ថានសាធារណៈឯកជន និងមន្ត្រីដៃគូអន្តរជាតិទាំងអស់ឱ្យជួបប្រទះតែជោគជ័យ សុភមង្គល រកស៊ីមានបាននិងឆ្នាំថ្មីជោគជ័យថ្មី ។

អង្គប្រជុំបានបញ្ចប់នៅវេលាម៉ោង ដប់ប្រាំពីរសែសិបប្រាំនាទីល្ងាចនៅថ្ងៃ ខែ ឆ្នាំ ដដែល ក្រោមបរិយាកាសរីករាយ ស្និទ្ធស្នាល យោគយល់គ្នា និងយកចិត្តទុកដាក់បំផុត ។

ភ្នំពេញ,ថ្ងៃទី ខែ មីនា ឆ្នាំ ២០០៨

លេខាកត់ត្រា

**បានឃើញ និង ឯកភាព**

**ប្រធានអង្គប្រជុំ**

ហ៊ីង ស៊ីដេត